មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# កំណត់ត្រាសង្ខេប
# កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា

ខែតុលា ឆ្នាំ២០១៤

## ខ្លឹមសារសង្ខេប

បទដ្ឋានអន្តរជាតិនានាទទួលស្គាល់ថា កុមារជាប់ចោទពីការរំលោភច្បាប់ព្រហ្មទណ្ឌ តម្រូវឱ្យមានការថែទាំ និងផ្តល់កិច្ចការពារជាពិសេស។ កុមារជាប់ចោទពីបទល្មើសព្រហ្មទណ្ឌមានសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ដូចគ្នានឹងមនុស្សពេញវ័យផងដែរ ព្រមទាំងទទួលបានកិច្ចការពារនានាបន្ថែមដើម្បីឆ្លុះបញ្ចាំងឱ្យឃើញថា កុមារខុសពីមនុស្សពេញវ័យក្នុងការវិវឌ្ឍន៍ផ្នែករាងកាយ និងផ្នែកសតិស្មារតី។ នៅពេលរៀបចំឱ្យមានយុត្តិធម៌ដល់អនីតិជន រដ្ឋត្រូវតែមាននីតិវិធីនានាដើម្បីធានាថា សិទ្ធិ និងកិច្ចការពារទាំងនេះត្រូវបានគេគោរពតាម និងធានាថា ផលប្រយោជន៍របស់កុមារត្រូវបានគេគិតគូរនៅគ្រប់ដំណាក់កាលទាំងអស់។

កំណត់ត្រាសង្ខេបនេះ វាយតម្លៃពីស្ថានភាពបច្ចុប្បន្ននៃប្រព័ន្ធយុត្តិធម៌អនីតិជននៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") ដែលផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ។ ផ្នែកដំបូងនៃកំណត់ត្រាសង្ខេបនេះគូសបញ្ជាក់ពីច្បាប់អន្តរជាតិ និងច្បាប់ជាតិទាក់ទិនទៅនឹងយុត្តិធម៌អនីតិជន ចំណែកផ្នែកទីពីរវាយតម្លៃពីការប្រតិបត្តិនូវសិទ្ធិអនីតិជននៅក្នុងប្រព័ន្ធព្រហ្មទណ្ឌតាមរយៈទិន្នន័យប្រមូលបានក្នុងអំឡុងពេលនៃការសង្កេតការណ៍សវនាការរយៈពេល៣ឆ្នាំ។ ផ្នែកបញ្ចប់ផ្តល់នូវអនុសាសន៍ជាក់លាក់សម្រាប់ការអនុវត្តន៍កំណែទម្រង់យុត្តិធម៌អនីតិជនដែលអាចត្រូវបានអនុម័តឡើងដើម្បីធានាថា ការរៀបចំ និងកិច្ចការពារអនីតិជននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌអនុលោមតាមបទដ្ឋានអន្តរជាតិ។ អនុសាសន៍សំខាន់ៗ ជូនទៅរាជរដ្ឋាភិបាលកម្ពុជា ("រដ្ឋាភិបាល") រួមមាន ៖

- អនុម័តសេចក្តីព្រាងច្បាប់ស្តីពីអនីតិជនជារឿងអាទិភាព។
- ធ្វើវិសោធនកម្មច្បាប់ដែលមានស្រាប់ដើម្បីធានាដល់ការអនុវត្តន៍ត្រឹមត្រូវ។
- រៀបចំវគ្គបណ្តុះបណ្តាលដោយឡែកសម្រាប់ចៅក្រម និងព្រះរាជអាជ្ញានៅមុនពេលចៅក្រម និងព្រះរាជអាជ្ញាកាន់សំណុំរឿងឬលើកយកករណីពាក់ព័ន្ធនឹងជនជាប់ចោទជាអនីតិជនមកកាត់ទោស និង
- ធានាថាការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងតែក្នុងករណីពិសេសប៉ុណ្ណោះ ជាវិធានការចុងក្រោយបង្អស់ និងមានថិរវេលាសមស្របខ្លីបំផុត។

  កំណត់ត្រាសង្ខេបនេះ គឺតាក់តែងឡើងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក) ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចំណុះឱ្យគណបក្សនយោបាយ ដែលធ្វើការដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយនៅ ទូទាំងប្រទេសកម្ពុជា។ ។

## និដ្ឋភាពទូទៅនៃក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន

### ច្បាប់អន្តរជាតិ

បទដ្ឋានអន្តរជាតិនានាដែលចែងអំពីយុត្តិធម៌អនីតិជនបានវិវឌ្ឍតាមរយៈអនុសញ្ញាដែលទទួលស្គាល់ជាអន្តរជាតិផ្សេងៗ គោលការណ៍ណែនាំ និងផែនការលម្អិតដើម្បីឱ្យមានកិច្ចការពារដោយប្រសិទ្ធភាពដល់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ អនុសញ្ញាទាំងនោះត្រូវអនុវត្តដោយផ្ទាល់នៅកម្ពុជា តាមមាត្រា ៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ចែងថា ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្ស[1] ("ស.ស.ស.ម") និងកតិកាសញ្ញា ព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ តាមរយៈការដាក់បញ្ចូល ស.ស.ស.ម និងអនុសញ្ញាស្ដីពីកុមារ[2] ដែលកម្ពុជាបានផ្ដល់សច្ចាប័ននៅឆ្នាំ១៩៩២។ អនុសញ្ញានេះត្រូវបានបញ្ជាក់សារជាថ្មី ឆ្នាំ២០០៧ តាមរយៈសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញដែលទទួលស្គាល់ថាច្បាប់អន្តរជាតិត្រូវអនុវត្តដោយផ្ទាល់ដោយតុលាការជាតិ។[3] បន្ថែមលើនេះ មាត្រា៤៨ នៃរដ្ឋធម្មនុញ្ញចែងថា "*រដ្ឋធានារក្សាការពារសិទ្ធិរបស់កុមារ ដែលមានចែងក្នុងអនុសញ្ញាស្ដីពីកុមារ*"។

អនុសញ្ញាស្ដីពីសិទ្ធិកុមារត្រូវបានមហាសន្និបាតអង្គការសហប្រជាជាតិអនុម័តនៅក្នុងខែឧសភា ឆ្នាំ ១៩៨៩ គឺជាលិខិតុបករណ៍សំខាន់ដែលបញ្ចូលនូវកិច្ចការពារអប្បបរមាដែលត្រូវអនុវត្តចំពោះអនីតិជននៅក្នុងប្រព័ន្ធយុត្តិធម៌។ អនុសញ្ញាស្ដីពីសិទ្ធិកុមារ ធានាដល់ការជំនុំជម្រះដោយយុត្តិធម៌ចំពោះកុមារជាប់ចោទពីការរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌ ព្រមទាំងជាអនុសញ្ញាសកលមួយដែលត្រូវបានបណ្ដាប្រទេសទាំងអស់នៅលើពិភពលោកបានផ្ដល់សច្ចាប័ន លើកលែងតែប្រទេសចំនួនពីរ។[4]

អនុសញ្ញាស្ដីពីសិទ្ធិកុមារទ្រទ្រង់ដោយគោលការណ៍សំខាន់ចំនួន ៤ ចំណុច (១) ការមិនរើសអើង (២) សិទ្ធិរស់រានមានជីវិត (៣) ការរស់នៅ និងការអភិវឌ្ឍន៍ និង (៤) គោរពដល់ទស្សនៈរបស់កុមារ។ មាត្រា ៣៧ និងមាត្រា ៤០ អនុសញ្ញាស្ដីពីសិទ្ធិកុមារទាក់ទងទាំងស្រុងទៅនឹងការរៀបចំកុមារក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ហើយមាត្រាទាំងពីរនេះត្រូវបានណែនាំតាមរយៈគោលការណ៍ទាំង ៤ ខាងលើនោះ។ ទន្ទឹមនេះ មាត្រាទាំងពីរ គូសបញ្ជាក់ពីសិទ្ធិនានាដែលអនុវត្តផងដែរចំពោះមនុស្សពេញវ័យ មាត្រាទាំងពីរនេះបន្ថែមការឧបត្ថម្ភ និងការការពារជាក់លាក់ដល់កុមារដែលត្រូវគេដកហូតសេរីភាពនៅក្នុងប្រព័ន្ធព្រហ្មទណ្ឌ។ មាត្រា ៣៧ ចែងពី

---

[1] ស.ស.ស.ម បានអនុម័តដោយមហាអង្គសន្និបាតអង្គការសហប្រជាជាតិនៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ អាចរកបានតាម៖ http://bit.ly/XYKoAd។

[2] អនុសញ្ញាស្ដីពីកុមារអនុម័តដោយមហាអង្គសន្និបាតអង្គការសហប្រជាជាតិ ដំណោះស្រាយលេខ៤៤/២៥ នៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ ១៩៨៩ អាចស្វែងរកបានតាម ៖ http://bit.ly/XYKurr។

[3] សេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាលេខ ០៩២/០០៣/២០០៧ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧ ស្ដីពីការអនុវត្តន៍សន្ធិសញ្ញាសិទ្ធិមនុស្សអន្តរជាតិដោយតុលាការកម្ពុជា។

[4] សហរដ្ឋអាមេរិកបានចុះហត្ថលេខា ប៉ុន្តែមិនបានផ្ដល់សច្ចាប័នទៅលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ ហើយប្រទេសសូម៉ាលីមិនបានចុះហត្ថលេខា ថែមទាំងមិនបានផ្ដល់សច្ចាប័នលើអនុសញ្ញាស្ដីពីសិទ្ធិកុមារ។

កិច្ចការពារក្នុងករណីមានការដកហូតសេរីភាពរបស់កុមារ រួមទាំងការមិនដាក់ទោសជាប់ពន្ធនាគារអស់មួយជីវិតទៅលើអនីតិជន ការចាប់ខ្លួន ការឃុំខ្លួន ហើយការដាក់ពន្ធនាគារគួរតែធ្វើឡើងក្នុងរយៈពេលសមរម្យខ្លីបំផុត និងជាវិធានការចុងក្រោយបង្អស់ ដែលសេចក្តីត្រូវការនិងអាយុរបស់បុគ្គលនោះត្រូវតែត្រូវបានគេគិតគូរ ហើយកុមារដែលត្រូវបានដកហូតសេរីភាពគួរតែត្រូវបានដាក់ឱ្យនៅដាច់ដោយឡែកពីមនុស្សពេញវ័យ។

**មាត្រា ៣៧ នៃ អនុសញ្ញាស្តីពីសិទ្ធិកុមារ ៖**

(ក) គ្មានកុមារណាម្នាក់ ត្រូវទទួលរងទារុណទណ្ឌកម្ម ឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្តន្ទាទោសឃោរឃៅ អមនុស្សធម៌ ឬបន្ថោកបន្ទាបឡើយ។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិតដោយគ្មានលទ្ធភាពដោះលែង មិនត្រូវដាក់ចំពោះបទល្មើស ដែលប្រព្រឹត្តដោយមនុស្សមានអាយុក្រោម ១៨ ឆ្នាំឡើយ។

(ខ) គ្មានកុមារណាម្នាក់ ត្រូវបានដកហូតសេរីភាពដោយខុសច្បាប់ ឬតាមអំពើចិត្តឡើយ។ ការចាប់ខ្លួន ការឃុំខ្លួន ឬការដាក់ពន្ធនាគារ ត្រូវធ្វើស្របតាមច្បាប់ នឹងត្រូវប្រើសម្រាប់តែវិធានការចុងក្រោយ និងសម្រាប់រយៈពេលខ្លីបំផុត។

(គ) កុមារណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការគិតគូរប្រកបដោយមនុស្សធម៌ ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាប់ពីកំណើតរបស់មនុស្ស និងគិតដល់សេចក្តីត្រូវការរបស់មនុស្សក្នុងវ័យកុមារ។ ជាពិសេស កុមារទាំងអស់ដែលត្រូវបានដកហូតសេរីភាព ត្រូវដាក់ឱ្យនៅដោយឡែកពីមនុស្សពេញវ័យ លើកលែងតែផលប្រយោជន៍ល្អបំផុតរបស់កុមារ មិនតម្រូវឱ្យធ្វើដូច្នេះ ហើយកុមារទាំងនេះ ត្រូវមានសិទ្ធិទាក់ទងជាមួយគ្រួសារខ្លួន តាមរយៈការឆ្លើយឆ្លង និងការជួបសួរសុខទុក្ខ លើកលែងតែក្នុងកាលៈទេសៈពិសេសចេញ។

(ឃ) កុមារដែលត្រូវបានដកហូតសេរីភាព មានសិទ្ធិទទួលបានភ្លាមៗនូវជំនួយផ្នែកច្បាប់ និងជំនួយសមស្របផ្សេងៗទៀត និងមានសិទ្ធិជំទាស់ភាពស្របច្បាប់នៃការដកហូតសេរីភាពខ្លួនចំពោះមុខតុលាការ ឬអាជ្ញាធរមានសមត្ថកិច្ច ឯករាជ្យ និងមិនលំអៀង និងមានសិទ្ធិទទួលបានសេចក្តីសម្រេចយ៉ាងឆាប់លើបណ្តឹងបែបនេះ។

មាត្រា ៤០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារបញ្ជាក់ច្បាស់ពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កុមារ និងកំណត់កាតព្វកិច្ចឱ្យរដ្ឋនានាពិចារណាទៅលើអាយុរបស់កុមារ និងឆន្ទៈពិតប្រាកដក្នុងការលើកកម្ពស់ការដាក់បញ្ចូលកុមារដើម្បីដើរតួនាទីស្ថាបនាក្នុងសង្គម ព្រមទាំងលើកស្ទួយឱ្យមានការបង្កើតច្បាប់ នីតិវិធីនានា អាជ្ញាធរ និងស្ថាប័ននានា ត្រូវអនុវត្តឱ្យបានពិតប្រាកចំពោះកុមារ។ ជាពិសេស មាត្រា ៤០ បង្ហាប់ថា រដ្ឋគួរបង្កើតវិធានការនានាដើម្បីដោះស្រាយលើករណីកុមារដោយមិនចាំបាច់មានវិធានការចុងក្រោយតាមនីតិវិធីតុលាការនោះទេ និងបង្កើតវិធានការផ្សេងពីនេះវិញ ដូចជា ការថែទាំ ការណែនាំ និងការតាមដាន ការប្រឹក្សាយោបល់ ការសាកល្បង ការបីបាច់ថែរក្សា ការអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងចំណោមវិធានការបែបនោះដទៃផ្សេងទៀត។

មានបទដ្ឋានអន្តរជាតិមិនចងកាតព្វកិច្ចបន្ថែមទៀត ដែលបទដ្ឋានទាំងនោះ ទោះយ៉ាងណា ផ្តល់នូវមូលដ្ឋានរឹងមាំសម្រាប់ការបកស្រាយ និងការអនុវត្តន៍ទៅលើវិធាននានាដូចមានចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ។ វិធានអប្បបរមាស្តង់ដាររបស់អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងអនីតិជន("វិធានប៉េកាំង")[5] គឺជាកិច្ចព្រមព្រៀងអន្តរជាតិសំខាន់លើកដំបូងដែលបានដាក់បញ្ចូលការណែនាំទូលំទូលាយលើវិធានអប្បបរមាស្តង់ដារសម្រាប់រៀបចំយុត្តិធម៌អនីតិជន។ វិធានប៉េកាំងមានគោលបំណងលើកស្ទួយសុខមាលភាពកុមារទៅតាមទំហំដែលអាចធ្វើទៅរួច កាត់បន្ថយភាពចាំបាច់នូវកិច្ចអន្តរាគមន៍ពីប្រព័ន្ធយុត្តិធម៌អនីតិជន និងឈានដល់ការកាត់បន្ថយនូវការខូចខាតដែលអាចបង្កឡើងតាមរយៈឥទ្ធិពលនៃនីតិវិធីយុត្តិធម៌ព្រហ្មទណ្ឌ។

ជាងនេះទៀត វិធានអង្គការសហប្រជាជាតិសម្រាប់ការពារអនីតិជនដែលត្រូវបានគេដកហូតសេរីភាព[6] បានអនុម័តដោយមហាសន្និបាតរបស់អង្គការសហប្រជាជាតិនៅក្នុងខែធ្នូឆ្នាំ១៩៩០ ដោយចែងលម្អិតនូវរបៀបដែលប្រព័ន្ធយុត្តិធម៌អនីតិជនគួរលើកតម្កើងសិទ្ធិ និងសុវត្ថិភាព ព្រមទាំងលើកស្ទួយដល់សុខមាលភាពផ្នែករូបរាងកាយ និងសតិបញ្ញារបស់អនីតិជន។ ក្នុងខែជាមួយគ្នានេះ មហាសន្និបាត អ.ស.ប បានអនុម័តផងដែរនូវគោលការណ៍ណែនាំអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ពិរុទ្ធភាពរបស់អនីតិជន ដែលណែនាំរដ្ឋនានាឱ្យអនុម័តនូវកម្មវិធីការពារនានាជាអាទិភាព និងការពារដល់ " *សុខុមាលភាព ការអភិវឌ្ឍន៍ សិទ្ធិ និងផលប្រយោជន៍របស់កុមារ*[7]។ ជាចុងក្រោយ នៅក្នុងឆ្នាំ១៩៩៧ គោលការណ៍ណែនាំសកម្មភាពលើកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌត្រូវបានបង្កើតឡើងផងដែរដើម្បីផ្តល់នូវក្របខ័ណ្ឌសម្រាប់រដ្ឋភាគីអនុវត្តអនុសញ្ញាស្តីពីសិទ្ធិកុមារក្នុងបរិបទនៃការរៀបចំយុត្តិធម៌អនីតិជន។[8]

## ច្បាប់ជាតិ

សិទ្ធិរបស់អនីតិជនត្រូវបានការពារក្រោមច្បាប់កម្ពុជា។ ប៉ុន្តែ ជាការកត់សម្គាល់ឃើញថា កម្ពុជាមិនទាន់មានការកំណត់ច្បាស់លាស់នូវច្បាប់ដោយឡែកណាមួយពាក់ព័ន្ធទៅនឹងសិទ្ធិកុមាការនោះទេ។ បទប្បញ្ញត្តិច្បាប់នានាធ្វើការកំណត់ផ្សេងគ្នាទៅលើអនីតិជន ដែលត្រូវដកស្រង់ចេញមកពីក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ("ក្រមនីតិវិធីព្រហ្មទណ្ឌ")។

មាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌមានភាពធូរលុង ខ្វះការប្តេជ្ញាចិត្តពិតប្រាកដចំពោះវិធានការ "តាមដានវិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ" ដល់អនីតិជន និងផ្តល់ការគូសបញ្ជាក់ផ្សេងគ្នាពីកិច្ចការ

---

[5] វិធានអប្បបរមាស្តង់ដារ អង្គការសហប្រជាជាតិសម្រាប់ការគ្រប់គ្រងលើអនីតិជន ("វិធានប៉េកាំង") បានអនុម័តដោយមហាសន្និបាតអ.ស.ប សេចក្តីសម្រេចលេខ ៤០/៣៣ នៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ១៩៨៥ អាចរកបានតាមរយៈ៖http://bit.ly/XYH2gv។

[6] មហាសន្និបាតអង្គការសហប្រជាជាតិ សេចក្តីសម្រេចលេខ ៤៥/១១៣ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ អាចរកបានតាមរយៈ៖ http://bit.ly/1sTwedY។

[7] គោលការណ៍ណែនាំអង្គការសហប្រជាជាតិដើម្បីទប់ស្កាត់ពិរុទ្ធភាពរបស់អនីតិជន បានអនុម័ត និងបានប្រកាសដោយមហាសន្និបាត អ.ស.ប ដំណោះស្រាយលេខ ៤៥/១១២ នៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩០ អាចរកបានតាមរយៈ http://bit.ly/XYImQv។

[8] គោលការណ៍ណែនាំសម្រាប់សកម្មភាពលើកុមារនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលត្រូវបានក្រុមប្រឹក្សាផ្នែកសេដ្ឋកិច្ច និងសង្គមបានផ្តល់អនុសាសន៍ ដំណោះស្រាយលេខ ១៩៩៧/៣០ នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ១៩៩៧ អាចរកបានតាមរយៈ ៖ http://bit.ly/XYHRGc ។

ពារដែលគួរត្រូវផ្តល់ដល់អនីតិជនដែលប្រព្រឹត្តបទល្មើស ប៉ុន្តែមិនបានផ្តល់វិធានការច្បាស់លាស់ដែលគួរត្រូវផ្តល់កិច្ចការពារនោះទេ។ ការប្តេជ្ញាទាំងនេះមិនមានវិសាលភាពត្រូវអនុវត្តផ្អែកតាមមូលដ្ឋានក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ ហើយក៏ពុំមានការកំណត់ច្បាស់លាស់នៃវិធាននីតិវិធីអនុវត្តសម្រាប់អនីតិជននោះដែរ។ ដូច្នេះមានចំណុចតិចតួចណាស់ក្រោមច្បាប់ជាតិបានបំពេញតួនាទីជាគោលការណ៍ណែនាំ សម្រាប់ការរៀបចំយុត្តិធម៌អនីតិជន។ បទប្បញ្ញត្តិជាតិពាក់ព័ន្ធទៅនឹងប្រព័ន្ធយុត្តិធម៌អនីតិជននឹងត្រូវវិភាគបន្ថែមនៅផ្នែកខាងក្រោម។

## ការវាយតម្លៃការអនុវត្តន៍បទដ្ឋានយុត្តិធម៌អនីតិជន

ការកំណត់អនីតិជនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌនៅកម្ពុជាត្រូវបានវាយតម្លៃតាមរបៀបពីរយ៉ាង។ ទីមួយ ច្បាប់ជាតិត្រូវបានវាយតម្លៃផ្ទុយទៅនឹងបទដ្ឋានអន្តរជាតិ ក្នុងការកំណត់ថាតើក្របខ័ណ្ឌច្បាប់កម្ពុជាមានលទ្ធភាពគ្រប់គ្រាន់ផ្តល់កិច្ចការពារដែលតម្រូវដោយច្បាប់អន្តរជាតិបានកម្រិតណា។ ទីពីរ កិច្ចការពារមានចែងនៅក្នុងក្របខណ្ឌច្បាប់កម្ពុជាត្រូវតែប្រៀបធៀបទៅនឹងតថភាព ដែលអនីតិជនប្រឈមនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន និងកិច្ចការពារតាមផ្លូវច្បាប់ទន់ខ្សោយប្រសិនបើមិនត្រូវបានគេអើពើទេនោះ។

គម្រោងសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក បានបានបង្កើតទិន្នន័យជាច្រើនស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា រួមទាំងការលើកឡើងនិយាយអំពីអនីតិជននៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។ គម្រោងបានសង្កេតសវនាការព្រហ្មទណ្ឌដើម្បីទទួលបានចំនួនទិន្នន័យនានា និងទិន្នន័យប្រកបដោយគុណភាពផ្តោតសំខាន់ទៅលើជាតុផ្សំផ្នែកនីតិវិធី និងជាតុផ្សំជាច្រើនតាមរយៈតារាងសង្កេតការណ៍សវនាការដែលជាការវាស់ស្ទង់នូវការប្រកាន់ខ្ជាប់តាមសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។

នៅចន្លោះខែសីហា ឆ្នាំ២០០៩ និងខែមិថុនា ឆ្នាំ២០១២ គម្រោងបានសង្កេតសវនាការនៅសាលាដំបូងរាជធានីភ្នំពេញ សាលាដំបូងខេត្តកណ្តាល សាលាដំបូងខេត្តបន្ទាយមានជ័យ និងសាលាដំបូងខេត្តរតនៈគិរី និងបានចេញផ្សាយរបាយការណ៍ប្រចាំឆមាសលើកទី៦ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌។[9] ការសង្កេតសវនាការសាលាដំបូងបានបង្ហាញទិន្នន័យសរុបចំនួន ២១៩ករណី ពាក់ព័ន្ធទៅនឹងអនីតិជន ក្នុងចំណោមករណីចំនួន ២,៥៥៨ នៃសវនាការដែលបានឃ្លាំមើល។

## អាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌ

មាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ១៨ឆ្នាំ អនុលោមតាមអនុសញ្ញាស្តីពីសិទ្ធិកុមារដែលកំណត់កុមារថា *"កុមារគឺជាមនុស្សមានអាយុក្រោម១៨ឆ្នាំ លើកលែងតែក្រោមច្បាប់ដែលត្រូវអនុវត្តចំពោះកុមារ នីតិភាពត្រូវបានកំណត់ទាបជាងនេះ"*។[10] ស្របពេលដែលអនុសញ្ញាស្តីពីសិទ្ធិកុមារព្រមទាំងកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន") មិនបានកំណត់ឱ្យបានច្បាស់លាស់នូវអាយុអប្បបរមានៃការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ អនុសញ្ញាស្តីពីសិទ្ធិកុមារតម្រូវឱ្យរដ្ឋនានា

---

[9] របាយការណ៍ប្រចាំឆមាសលើកទី៦ ស្តីពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នៅកម្ពុជា អាចរកបានតាមរយៈ ៖ //bit.ly/M7mkET។

[10] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ១

កំណត់អាយុអប្បបរមាយ៉ាងទាប ដែលកុមារត្រូវបានសន្មតថាមិនមានសមត្ថភាពរំលោភបំពានច្បាប់ព្រហ្មទណ្ឌ ។[11] លើសពីនេះទៀត គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ ជាស្ថាប័នទទួលបន្ទុកផ្នែកតាមដានការអនុវត្តន៍អនុសញ្ញាស្តីពីសិទ្ធិកុមាររបស់អង្គការសហប្រជាជាតិបានធ្វើសេចក្តីសន្និដ្ឋានថា អាយុ១២ឆ្នាំគឺជាអាយុអប្បបរមាតិចបំផុតដែលមានការទទួលស្គាល់ជាអន្តរជាតិពីការទទួលខុសត្រូវព្រហ្មទណ្ឌ។[12]

បើទោះបីជាអាយុទទួលខុសត្រូវព្រហ្មទណ្ឌតាមច្បាប់កម្ពុជា១៨ឆ្នាំក៏ដោយក្តី ក៏ធន្ទានុសិទ្ធិផ្តល់ជូនចៅក្រមក្រោមមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌមានលក្ខណៈទូលំទូលាយ ដែលអនុញ្ញាតឱ្យចៅក្រមអាច "*ប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ*" ដែលនេះជាការគួរឱ្យព្រួយបារម្ភ។ ករណីនេះ អនុញ្ញាតឱ្យចៅក្រមកំណត់កុមារអាយុក្រោម១៨ឆ្នាំទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នានឹងមនុស្សពេញវ័យដែរ។ ការប៉ាន់ប្រមាណរបស់អ្នកជំនាញមកពីសង្គមស៊ីវិលក្នុងអំឡុងពេលប្រឹក្សាយោបល់បានលើកឡើងថា កុមាររហូតដល់ ៥០% ត្រូវបានចោទប្រកាន់ពីបទឧក្រិដ្ឋ ដោយត្រូវបានចាត់ទុកថាជាមនុស្សពេញវ័យនៅក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ។[13] ការរួមចំណែកបង្កឱ្យមានបញ្ហានេះគឺដោយសារកង្វះការចែងលក្ខខណ្ឌអាយុរបស់កុមារឱ្យបានត្រឹមត្រូវ ដោយសារតែទេសន្តរប្រវេសន៍ខាងក្នុង ការបណ្តេញចេញដោយបង្ខំ ឬរឿងសាមញ្ញនោះគឺដោយសារអាជ្ញាធរមូលដ្ឋានខកខានផ្តល់ការចុះសំបុត្រកំណើតឱ្យបានគ្រប់គ្រាន់។[14]

## ការឃុំខ្លួនបណ្តោះអាសន្ន

បទដ្ឋានអន្តរជាតិហាមប្រាមយ៉ាងខ្លាំងដល់ការឃុំខ្លួនជាបណ្តោះអាសន្នពាក់ព័ន្ធនឹងអនីតិជន ច្រើនជាងករណីពាក់ព័ន្ធជាមួយជនជាប់ចោទជាមនុស្សពេញវ័យ។ ក្នុងករណីភាគច្រើន ផលប្រយោជន៍ល្អបំផុតសម្រាប់កុមារគឺត្រូវការពារពួកគេមិនអោយឃ្លាតចេញពីឪពុកម្តាយ។ ការឃុំខ្លួនកុមារក្នុងនោះរួមទាំងក្រោយការឃុំខ្លួន និងនៅពេលមុនការជំនុំជម្រះ គួរតែត្រូវបានជៀសវាងតាមកាលៈទេសៈណាមួយដែលអាចធ្វើទៅបាន ហើយធ្វើឡើងតែក្នុងវិធានការចុងក្រោយបង្អស់ក្នុងរយៈពេលសមរម្យខ្លីបំផុតប៉ុណ្ណោះ។ នេះគឺដោយសារតែ អនីតិជនងាយប្រឈមខ្លាំងណាស់ទៅនឹងអំពើហិង្សា និងការកេងចំណេញផ្នែកផ្លូវភេទនៅក្នុងពេលឃុំខ្លួន ព្រម

---

[11] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០ (៣) (ក) "៣. រដ្ឋភាគីត្រូវខិតខំលើកស្ទួយការបង្កើតច្បាប់ នីតិវិធី អាជ្ញាធរ និងស្ថាប័នត្រូវអនុវត្តឱ្យបានជាក់លាក់ចំពោះកុមារដែលត្រូវបានចោទប្រកាន់ ឬទទួលដឹងថាបានរំលោភក្រមព្រហ្មទណ្ឌ ហើយជាពិសេស ៖ (ក) ធ្វើការកំណត់អាយុអប្បបរមាទាបបំផុតដែលកុមារនឹងត្រូវបានសន្មតថាមិនមានសមត្ថភាពរំលោភបំពានច្បាប់ព្រហ្មទណ្ឌ។

[12] គណៈកម្មាធិការទទួលបន្ទុកសិទ្ធិកុមារ អធិប្បាយទូទៅលេខ ១០ ៖ សិទ្ធិរបស់កុមារនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន កថាខ័ណ្ឌ ៣២ អាចរកបានតាមរយៈ ៖ http://bit.ly/VhCL63។

[13] ប្រភពខាងលើ។

[14] ការត្រួតពិនិត្យជាសាកល និងជាទៀងទាត់ ៖ សារណាការត្រួតពិនិត្យជាសកល និងជាទៀងទាត់ស្តីពីសិទ្ធិកុមារនៅព្រះរាជាណាចក្រកម្ពុជា(កម្ពុជា) ដោយអង្គការចម្រុះទទួលបន្ទុកផ្នែកសិទ្ធិរបស់កុមារ(ឆ្នាំ២០០៩-២០១៣)។

ទាំងដើម្បីទប់ស្កាត់បដិកិរិយាជាមួយជនល្មើសជាមនុស្សពេញវ័យ ដែលអាចកាត់បន្ថយនូវសភាពនៃនីតិសម្បទាដោយជោគជ័យ។[15]

តាមទ្រឹស្តី ច្បាប់ជាតិ និងនីតិវិធីរបស់កម្ពុជា ផ្តល់កិច្ចការពារមួយចំនួនប្រឆាំងទៅនឹងការឃុំខ្លួនជាបណ្តោះអាសន្នទៅលើអនីតិជន។ មាត្រា ២១២ នៃក្រមនីតិវិធីព្រហ្មទណ្ឌហាមប្រាមការឃុំខ្លួនបណ្តោះអាសន្នចំពោះជនទាំងឡាយណាដែលមានអាយុក្រោម ១៤ ឆ្នាំ។ ទោះបីជា មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌធ្វើការកំណត់ការឃុំខ្លួនជាបណ្តោះអាសន្នចំពោះជនទាំងឡាយណាដែលមានអាយុចន្លោះពី ១៤ ដល់ ១៨នោះក្តី ក៏មាត្រានេះមិនបានចែងឱ្យច្បាស់លាស់ពីការឃុំខ្លួនបណ្តោះអាសន្ននោះទេ។ នេះជាការគួរព្រួយបារម្ភ ហើយផ្ទុយទៅនឹងមាត្រា ៩ (១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលកំណត់ការសាកល្បងខ្ពស់ជុំវិញភាពចាំបាច់នៅពេលបំបែកកុមារចេញពីឪពុកម្តាយ ដែលផ្ទុយទៅនឹងឆន្ទៈរបស់ពួកគេ។

ចំនួន ៨៧% នៃអនីតិជនត្រូវបានគេដាក់អោយស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន យោងតាមនិន្នន័យរបស់ ម.ស.ម.ក ករណីនេះច្បាស់ណាស់ថា ការរៀបចំយុត្តិធម៌អនីតិជនរបស់កម្ពុជាជាលក្ខណៈប្រព័ន្ធខកខានក្នុងការប្រតិបត្តិតាមច្បាប់អន្តរជាតិស្តីអំពីការឃុំខ្លួនបណ្តោះអាសន្ន។ ការដាក់ពន្ធនាគារទៅលើអនីតិជន ជាពិសេស អនីតិជនដែលមិនទាន់បានកាត់ទោស ត្រូវធ្វើឡើងតែក្នុងវិធានការចុងក្រោយបង្អស់តែប៉ុណ្ណោះ។ ការដែលថា ការឃុំខ្លួនបណ្តោះអាសន្នគឺរឿងធម្មតាសម្រាប់ជនជាប់ចោទជាអនីតិជនដែលមានចំនួនភាគច្រើនបំផុតនោះ បង្ហាញពីបរាជ័យដ៏ធំក្នុងការសន្មតពីភាពគ្មានទោស និងសិទ្ធិទទួលបានសេរីភាព។ ម្យ៉ាងវិញទៀត ករណីនេះកំពុងតែឱ្យសញ្ញាថាភាពរីករាលដាលនៃការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជនបានកើនឡើងច្រើនជាងការឃុំខ្លួនបណ្តោះអាសន្នទៅលើមនុស្សពេញវ័យក្នុងរយៈពេលសង្កេតសវនាការកន្លងមកនេះ គឺចន្លោះពីខែកក្កដា ដល់ខែធ្នូ ឆ្នាំ២០១១ ដោយ៩៥% នៃអនីតិជនពាក់ព័ន្ធក្នុងសំណុំរឿងបានសង្កេត ត្រូវបានគេដាក់អោយស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយមនុស្សពេញវ័យមាន ៧០% ហើយនៅចន្លោះពីខែមករា ដល់ខែមិថុនា ឆ្នាំ២០១២ ការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជនមាន ៩១,៥% ខណៈដែលការឃុំខ្លួនបណ្តោះអាសន្នទៅលើមនុស្សពេញវ័យមាន៧១%។

និន្នន័យស្តីពីអនីតិជនស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នបង្ហាញថាប្រព័ន្ធយុត្តិធម៌មិនបានអនុវត្តឱ្យបានពេញលេញនូវប្រព័ន្ធយុត្តិធម៌អនីតិជនទាក់ទងទៅនឹងសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌នោះទេ ព្រោះសិទ្ធិទាំងនេះពាក់ព័ន្ធយ៉ាងជាក់លាក់ជាមួយកុមារ។ ករណីនេះប្រហែលជាបង្ហាញពីកង្វះខាតផ្នែកធនធានសង្គម និងរចនាសម្ព័ន្ធ ហើយគាំទ្រឱ្យមានជម្រើសផ្សេងជំនួសវិញដើម្បីជួយសម្រួលដល់ការសន្មតថាអនីតិជនមិនគួរត្រូវបានឃុំខ្លួនរហូតដល់ការជំនុំជម្រះឡើយ។

អនុប្រធានតុលាការខេត្តបន្ទាយមានជ័យបានពន្យល់ដល់បុគ្គលិកសង្កេតការណ៍សវនាការរបស់ ម.ស.ម.ក ថា ហេតុផលសំខាន់មួយចំនួនក្នុងការកំណត់ការឃុំខ្លួនបណ្តោះអាសន្នក្នុងករណីពាក់ព័ន្ធទៅនឹងជនជាប់

[15] គណៈកម្មាធិការទទួលបន្ទុកសិទ្ធិរបស់កុមារ អត្ថាធិប្បាយទូទៅលេខ ១០ ៖ សិទ្ធិរបស់កុមារក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន កថាខណ្ឌទី ៨៥ អាចរកបានតាមរយៈ ៖ http://bit.ly/VhCL63។

ចោទជាអនីតិជន គឺដោយសារសភាពធ្ងន់ធ្ងរនៃបទល្មើស និងថា ជនជាប់ចោទមិនមានអាស័យដ្ឋានពិតប្រាកដ ព្រមទាំងពុំមានធនធានគ្រប់គ្រាន់ដើម្បីឃ្លាំមើលការត្រួតពិនិត្យតាមផ្លូវតុលាការ។[16] សមាជិកចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញគូសបញ្ជាក់ឧទាហរណ៍របស់ជនជាប់ចោទដោយសំដៅទៅលើអាយុ និងការប្រព្រឹត្តបទល្មើសបន្ថែមជាហេតុផលនៅពីក្រោយតួលេខខ្ពស់នៃការឃុំខ្លួនអនីតិជន។[17] នេះជារឿងសំខាន់ដែលចៅក្រមធ្វើសេចក្តីសម្រេចលើការឃុំខ្លួនជាបណ្តោះអាសន្នអនុលោមតាមបទប្បញ្ញត្តិនៃមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមិនបានបញ្ចូលនូវភាពធ្ងន់ធ្ងរនៃបទល្មើសជាលក្ខណៈវិនិច្ឆ័យមួយសម្រាប់កំណត់ការឃុំខ្លួនបណ្តោះអាសន្ននោះ។ ទន្ទឹមនេះ ករណីជនជាប់ចោទជាមនុស្សពេញវ័យ មានការតម្រូវច្បាស់លាស់ចំពោះបទប្បញ្ញត្តិនៃធនធានគ្រប់គ្រាន់ដើម្បីធ្វើការត្រួតពិនិត្យតាមផ្លូវតុលាការដែលជាតថភាព និងជាជម្រើសដែលអាចធ្វើបានក្រៅពីការឃុំខ្លួនបណ្តោះអាសន្ន។

ករណីសិក្សាទី១

ការជំនុំជម្រះក្តីបានសង្កេតនៅសាលាដំបូងរាជធានីភ្នំពេញនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២ពាក់ព័ន្ធទៅនឹងអនីតិជនជាបងប្អូនបង្កើតចំនួនពីររូប។ អនីតិជនជាប្អូនមានអាយុ១៤ឆ្នាំនៅពេលប្រព្រឹត្តបទល្មើស ដែលត្រូវបានកាត់ទោសពីបទចោរកម្មក្រោមមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ ហើយត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល១ឆ្នាំ។ អនីតិជនជាបង មានអាយុ១៧ឆ្នាំ ត្រូវបានកាត់ទោសពីបទទទួលផលចោរកម្មក្រោមមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ និងត្រូវបានតុលាការកាត់ទោសដាក់ពន្ធនាគាររយៈពេល ២ឆ្នាំ ដោយព្យួរទោសរយៈពេល ១ឆ្នាំ។ មានការចោទប្រកាន់ថា ក្មេងប្រុសជាប្អូនបានលួចគ្រឿងអលង្ការពីផ្ទះនៅកន្លែងខ្លួនធ្វើការ ហើយបានប្រគល់គ្រឿងអលង្ការមានតម្លៃ២៧០០ដុល្លានោះទៅបងប្រុសខ្លួនដើម្បីរក្សាទុក។ ឪពុកម្តាយរបស់ក្មេងទាំងនេះត្រូវបានតុលាការបង្គាប់អោយសងជំងឺចិត្តចំនួន ២,៦០០ដុល្លាទៅអោយដើមបណ្តឹងរដ្ឋប្បវេណី។

បើទោះជាការកាត់ទោសនោះអនុលោមតាមលក្ខខណ្ឌតម្រូវទោសអប្បបរមាសម្រាប់កុមារនោះក៏ដោយ ក៏មានការព្រួយបារម្ភថាវិធីផ្សេងៗនៃការកាត់ទោសមិនត្រូវបានគិតគូរនៅក្នុងអំឡុងពេលជំនុំជម្រះក្តីនោះ។ ករណីនេះគួរត្រូវបានលើកឡើងថា ការដាក់កុមារក្នុងពន្ធនាគារចំពោះបទមជ្ឈិមរយៈពេល១ឆ្នាំគឺមិនសមហេតុផលទាល់តែសោះ ហើយជាការផ្ទុយទៅនឹងការចម្រើនលូតលាស់រយៈពេលយូរវែង និងសុខមាលភាពរបស់កុមារ។

អនីតិជនជាប្អូន បានរត់គេចពីការចាប់ខ្លួន ហើយអវត្តមាននៅពេលជំនុំជម្រះក្តី។ ប៉ុន្តែ អនីតិជនជាបង ត្រូវបានចាប់ខ្លួននៅថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២ និងត្រូវស្ថិតនៅក្នុងការឃុំខ្លួនបណ្តោះអាសន្នអស់រយៈពេល៥

[16] កិច្ចសន្ទនារបស់ ម.ស.ម.ក ជាមួយអនុប្រធានតុលាការខេត្តបន្ទាយមានជ័យចៅក្រម អ៊ិត សម្ផស្ស ថ្ងៃទី ១៣ ខែកញ្ញា ឆ្នាំ២០១២។

[17] កិច្ចសន្ទនារបស់ ម.ស.ម.ក ជាមួយ អនុប្រធាន ប្រធានចៅក្រម ព្រះរាជអាជ្ញារង និងមន្ត្រីរដ្ឋបាលរបស់តុលាការភ្នំពេញ ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១២។

ខែរហូតដល់កាលបរិច្ឆេទនៃការជំនុំជម្រះក្តីនៅថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១២។ ករណីនេះជាការគួរព្រួយបារម្ភ ព្រោះថាមិនត្រឹមតែមិនគួរឃុំខ្លួននៅមុនពេលជំនុំជម្រះ ដែលត្រូវគិតថាជាជម្រើសចុងក្រោយបង្អស់ប៉ុណ្ណោះទេប៉ុន្តែរយៈពេលនៃការឃុំខ្លួននោះមិនគួរហួសរយៈពេល៤ខែនោះដែរ[18]ក្នុងករណីបទមជ្ឈិមចំពោះកុមារមានអាយុពី១៦ ដល់អាយុ១៨ឆ្នាំ។ ក្នុងករណីការឃុំខ្លួនបណ្តោះអាសន្នមានរយៈពេលហួសចិរវេលាអនុញ្ញាត បង្ហាញថាជាការមិនគោរពទាំងស្រុងដល់សិទ្ធិរបស់កុមារ និងជាការរីករាលដាល ព្រមទាំងជារឿងសាមញ្ញជុំវិញការឃុំខ្លួននៅមុនពេលការជំនុំជម្រះរបស់តុលាការ។

បន្ថែមលើការព្រួយបារម្ភនោះ កុមារក្នុងតុលាការស្ថិតនៅក្នុងឯកសណ្ឋានពន្ធនាគារ ដោយបានរំលោភសិទ្ធិត្រូវបានសន្មតថាគ្មានទោសរបស់អនីតិជន។[19] ករណីនេះបង្ហាញថា មិនត្រឹមតែមិនគោរពដល់សិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ទេ ប៉ុន្តែបង្ហាញអោយឃើញពីកង្វះខាតខាងការយល់ដឹងក្នុងចំណោមចៅក្រមទៅលើការថែទាំបន្ថែម និងឆន្ទានុសិទ្ធិដែលគួរត្រូវបានគេបង្ហាញដល់កុមារក្នុងពេលដំណើរការនីតិវិធីក្តី។

## ភាពឯកជនរបស់អនីតិជន

ការជំនុំជម្រះក្តីព្រហ្មទណ្ឌពាក់ព័ន្ធនឹងមនុស្សពេញវ័យគួរត្រូវធ្វើឡើងជាសាធារណៈទូទៅដើម្បីស្របតាមសិទ្ធិទទួលបានសវនាការជាសាធារណៈ។ ប៉ុន្តែ ក្រោមច្បាប់អន្តរជាតិ នៅពេលការជំនុំជម្រះក្តីពាក់ព័ន្ធនឹងអនីតិជន គឺជាធម្មានុរូបត្រូវធ្វើការរឹតត្បិតបុគ្គលដែលចូលរួមក្នុងការជំនុំជម្រះក្តីនោះ និងរឹតត្បិតការធ្វើរបាយការណ៍ក្នុងគោលបំណងដើម្បីការពារអនីតិជនពីផលប៉ះពាល់ដែលអាចបង្កមកពីការផ្សព្វផ្សាយជាសាធារណៈជ្រុលពេក និងដើម្បីបញ្ចៀសភាពអាម៉ាស។

មាត្រា ៤០ (២)(ខ) (៧) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា "*រដ្ឋភាគីត្រូវគោរពយ៉ាងពេញលេញនូវសិទ្ធិនៃជីវិតឯកជនរបស់កុមារនៅក្នុងគ្រប់ដំណាក់កាលនៃនីតិវិធី*"។ ក.អ.ស.ព.នគាំទ្របន្ថែមដល់គោលការណ៍នេះតាមរយៈការបែងចែកបន្ថែមរវាងគោលការណ៍សកលនៃសិទ្ធិទទួលបានសវនាការជាសាធារណៈសម្រាប់មនុស្សពេញវ័យ និងរក្សាទុកនៅក្នុងគោលការណ៍សំខាន់ជុំវិញភាពឯកជនរបស់អនីតិជន។[20]

ទិន្នន័យឃ្លាំមើលសវនាការរបស់ ម.ស.ម.ក បង្ហាញថា ការរៀបចំយុត្តិធម៌អនីតិជននៅកម្ពុជាខកខានពុំបានផ្តល់ភាពឯកជនតម្រូវដោយច្បាប់អន្តរជាតិ។ ករណីចំនួនតែ ៣ ប៉ុណ្ណោះ ក្នុងចំណោមករណីចំនួន២១៩ បានឃ្លាំមើល ត្រូវបានគេអនុវត្តវិធានការដើម្បីការពារដល់ភាពឯកជនរបស់អនីតិជន។

[18] មាត្រា២១៤ នៃក្រមព្រហ្មទណ្ឌ។

[19] អនុសញ្ញាស្តីពីសិទ្ធិកុមារ មាត្រា ៤០(២)(ខ)(១) ក.អ.ស.ព.ន មាត្រា ១៤ (២) និង ស.ស.ស.ម មាត្រា១១។

[20] មាត្រា១៤ (១)។

ការចូលរួមជាសាធារណៈអាចត្រូវបានរឹតត្បិតដើម្បីការពារដល់ភាពឯកជនរបស់អនីតិជន ឧទាហរណ៍ដូចជា ការរៀបចំបន្ទប់សវនាការដាច់ដោយឡែកមួយ និងមានការរឹតត្បិតចំពោះករណីពាក់ព័ន្ធជាមួយអនីតិជន។ ក្នុងករណីមិនអាចធ្វើដូច្នោះបានទេ សាធារណៈជន (លើកលែងតែឪពុកម្តាយ ឬអាណាព្យាបាលតាមច្បាប់) មិនគួរត្រូវបានអនុញ្ញាតឱ្យចូលរួមសវនាការនោះទេ។ ឈ្មោះរបស់ជនជាប់ចោទជាអនីតិជន ឬក៏ព័ត៌មានលម្អិតបញ្ជាក់ពីអត្តសញ្ញាណដទៃទៀត មិនគួរត្រូវបានគេដាក់បង្ហាញនៅលើបញ្ជរផ្តល់ព័ត៌មានសាធារណៈនោះឡើយ។ ភាពឯកជនរបស់អនីតិជនអាចត្រូវបានការពារបន្ថែមទៀតតាមរយៈការប្រើប្រាស់ឧបករណ៍ដូចជាប្រព័ន្ធថតរូបភាពវីដេអូជាដើម។ នៅកម្ពុជា ដូចជាប្រព័ន្ធថតរូបភាពវីដេអូត្រូវបានគេបំពាក់នៅក្នុងបន្ទប់សវនាការមួយចំនួន បើទោះបីជាតាមការសង្កេតរបស់ ម.ស.ម.ក ឃើញថាប្រព័ន្ធថតរូបភាពវីដេអូទាំងនោះមិនត្រូវបានគេប្រើប្រាស់ក៏ដោយក្តី។

នៅពេលធ្វើការបង្ហាញរបកគំហើញរបស់ ម.ស.ម.ក មន្ត្រីសាលាដំបូងខេត្តបន្ទាយមានជ័យបានអះអាងថា ចៅក្រមបានសម្រេចការពារភាពឯកជនរបស់ជនជាប់ចោទជាអនីតិជនចំពោះតែបទល្មើសជាក់លាក់ដូចការរំលោភសេពសន្ថវៈជាដើម[21] ខណៈមានកិច្ចប្រជុំស្រដៀងគ្នានេះមួយនៅសាលាដំបូងរាជធានីភ្នំពេញបានគូសបញ្ជាក់ថាគ្មានបទប្បញ្ញត្តិជាក់លាក់តម្រូវឱ្យតុលាការបំពាក់កាមេរ៉ាក្នុងសវនាការចំពោះករណីពាក់ព័ន្ធទៅនឹងជនជាប់ចោទជាអនីតិជននោះឡើយ។[22]

ករណីសិក្សាទី២

ឧទាហរណ៍មួយនៃវិធានការដែលអាចត្រូវធ្វើឡើងដើម្បីការពារដល់ភាពឯកជនរបស់អនីតិជនគឺត្រូវបានបញ្ជាក់ដោយករណីមួយដែលភាពឯកជនរបស់អនីតិជនត្រូវបានការពារ។ ការជំនុំជម្រះធ្វើឡើងនៅសាលាដំបូងរាជធានីភ្នំពេញ និងករណីពាក់ព័ន្ធនឹងអនីតិជនអាយុ ១៥ឆ្នាំម្នាក់ ត្រូវបានតុលាការចោទប្រកាន់ពីបទ "រំលោភដោយមានស្ថានទម្ងន់ទោសទៅលើជនរងគ្រោះ" ក្រោមមាត្រា ២៤១ នៃក្រមព្រហ្មទណ្ឌ។ នៅថ្ងៃទី ១៩ ខែមករា ឆ្នាំ២០១១ ជនរងគ្រោះជាក្មេងស្រីមានអាយុ៥ឆ្នាំ បានដើរទៅផ្ទះរបស់ជនជាប់ចោទដើម្បីមើលទូរទស្សន៍។ ជនជាប់ចោទបានចាប់ចើបនាង និងបានប្រាប់ឱ្យនាងស្រាតសំពត់ចេញមុនពេលចាប់រំលោភ។ ក្នុងអំឡុងពេលជំនុំជម្រះ មានការដាក់នាំងបាំងដើម្បីការពារភាពឯកជនរបស់ជនជាប់ចោទអនីតិជន។ ម្យ៉ាងវិញទៀត ជនជាប់ចោទត្រូវបានគេនិយាយថាមានបញ្ហាស្មារតី យោងតាមឪពុករបស់ជនជាប់ចោទ និងមេធាវី ដូច្នេះហើយចាំបាច់ត្រូវការកិច្ចការពារបន្ថែម។

[21] កិច្ចសន្ទនារបស់ ម.ស.ម.ក ជាមួយចៅខេត្តចំនួនពីររូប គឺលោកចៅក្រម អ៊ឹម វណ្ណៈ និងចៅក្រម ជាម ច័ន្ទពិសិដ្ឋ ថ្ងៃទី២៩ ខែសីហា ឆ្នាំ ២០១៣។

[22] កិច្ចសន្ទនារបស់ ម.ស.ម.ក ជាមួយអនុប្រធានសាលាដំបូងលោកចៅក្រម អឿង សៀង និងចៅក្រម កោ វណ្ណី ព្រះរាជអាជ្ញារង សុខ រឿន និងចៅក្រមបួនរូបផ្សេងទៀតគឺ ចៅក្រម សេង នាង ចៅក្រម អ៊ី ឋាវរៈ ចៅក្រម សែម សក្តិកូឡា និងអ្នកស្រីចៅក្រម ចាំង ស៊ីណាត ថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០១៣។

នេះជាករណីមួយក្នុងចំណោមករណីចំនួនពីរពាក់ព័ន្ធទៅនឹងវិធានការធ្វើឡើងដើម្បីការពារអនីតិជនក្នុងចំណោមសំណុំរឿងចំនួន២១៩ ករណីដែលបានកត់ត្រាទុក។

**ការកាត់ទោស**

មាត្រា ៣ (១) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារចែងថា ផលប្រយោជន៍ល្អបំផុតរបស់កុមារ ត្រូវតែយកចិត្តទុកដាក់ជាចម្បង នៅពេលបង្គាប់ ឬកំណត់ទោសទៅលើអនីតិជនដែលរកឃើញថាបានរំលោភបំពានលើច្បាប់ព្រហ្មទណ្ឌ។ មាត្រា ៣៧ (ខ) កំណត់ឱ្យតុលាការទទួលខុសត្រូវក្នុងការពិចារណាទៅលើការដាក់ពន្ធនាគារទៅលើអនីតិជនជាវិធានការមួយចុងក្រោយបង្អស់ដែលត្រូវធ្វើឡើងក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ។ មាត្រា ៤០ បញ្ជាក់ថា "*ការថែទាំ ការណែនាំ ការបង្គាប់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យ ការប្រឹក្សាយោបល់ ការសាកល្បង ការចិញ្ចឹមបីបាច់ ការអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និង វិធីក្រៅពីនេះដើម្បីទទួលបានការថែទាំពីស្ថាប័ន*" គួរតែត្រូវបានធ្វើឡើងជាចម្បងជាជាងការដាក់ពន្ធនាគារ។

ច្បាប់ពាក់ព័ន្ធការកាត់ទោសទៅលើអនីតិជនផ្តល់ឆន្ទានុសិទ្ធិពេញលេញដល់តុលាការនូវការកាត់ទោស។ ទោះបីជាមាត្រា ៣៩ នៃក្រមព្រហ្មទណ្ឌបញ្ជាក់ពីទោសមិនជាប់ឃុំចំពោះអនីតិជនដោយចែងថា អនីតិជនដែលប្រព្រឹត្តបទល្មើសគួរតែជាកម្មវត្ថុនៃការត្រួតពិនិត្យ ការអប់រំ ការការពារ និងការផ្តត់ផ្គង់នោះក្តី ក៏នេះអនុញ្ញាតឱ្យអនីតិជនមានការទទួលទោសព្រហ្មទណ្ឌផងដែរ ប្រសិនបើ "*កាលៈទេសៈតម្រូវ*"។ ក្នុងករណីតុលាការខ្វះការបណ្តុះបណ្តាលដែលពាក់ព័ន្ធ និងភាពប្រែប្រួលទាកទិនជាមួយអនីតិជន លទ្ធផលធម្មតាគឺថា ការដាក់ពន្ធនាគារត្រូវបានធ្វើឡើងស្ទើរតែគ្រប់ករណីទាំងអស់។

ភាពរាលដាលទូទៅជុំវិញការទោសជាប់ឃុំចំពោះអនីតិជនដែលរកឃើញមានពិរុទ្ធភាព គឺពិតជាគួរឱ្យព្រួយបារម្ភខ្លាំងណាស់។ ចៅក្រមសម្តែងឡើងនូវការមិនគោរពឱ្យបានស្មោះត្រង់ចំពោះច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលលើកទឹកចិត្តមិនឱ្យមានទោសជាប់ឃុំ។ ម.ស.ម.ក មានព័ត៌មានតែមួយប៉ុណ្ណោះអំពីករណីមួយក្នុងអំឡុងពេលការសង្កេតសវនាការរបស់ខ្លួន នៅពេលដែលចៅក្រមផ្តល់ការពិចារណាមួយចំនួនក្នុងការកំណត់ទោសមិនជាប់ឃុំដល់ជនជាប់ចោទជាអនីតិជនម្នាក់។ ទោះយ៉ាងណាក្តីក្នុងករណីនោះ ចៅក្រមបានកាត់ទោសអនីតិជននោះដាក់ពន្ធនាគាររយៈពេល ៣ ឆ្នាំ ៦ ខែ ដោយចៅក្រមបានឱ្យការសាកល្បងរយៈពេល ៣ឆ្នាំ។ ដូច្នោះ អនីតិជននោះបានអនុវត្តទោសត្រឹមតែ ៦ខែ ជំនួសទោស ៣ឆ្នាំកន្លះក្នុងពន្ធនាគារ។ តួលេខទាំងនេះគឺជាក្តីបារម្ភធ្ងន់ធ្ងរ និងមិនស្របទាល់តែសោះជាមួយច្បាប់អន្តរជាតិ និងច្បាប់ជាតិ។

បើទោះបីជាកម្ពុជាមានក្របខ័ណ្ឌច្បាប់ ដែលចែងកំណត់លក្ខណៈផ្សេងគ្នានៃលើអនីតិជនដែលត្រូវបានកត់ទោស ការអនុវត្តន៍ច្បាប់នេះគឺធ្វើឡើងតាមកាលៈទេសៈ ជាជាងការអនុវត្តន៍តាមទម្លាប់។ ទិន្នន័យដែលប្រមូលបានបង្ហាញពីកង្វះផ្នែកធនធានសង្គម និងច្បាប់ ព្រមទាំងរចនាសម្ព័ន្ធដើម្បីផ្តត់ផ្គង់ដល់តុលាការក្នុងការអនុវត្តន៍ច្បាប់។ តំណាងនៃសាលាដំបូងខេត្តបន្ទាយមានជ័យបានពន្យល់ថា តុលាការ មានបំណងកំណត់ទោស

មិនជាប់ឃុំទៅលើជនជាប់ចោទជាអនីតិជន ប៉ុន្តែមានបញ្ហាលំបាកក្នុងការអនុវត្តន៍ដោយសារតែកង្វះវិធានការត្រួតពិនិត្យ។[23] ជាងនេះទៀត មជ្ឈមណ្ឌលនីតិសម្បទាយុវជន ជាឧទាហរណ៍ស្រាប់មិនដំណើរការដោយសារតែកង្វះមូលនិធិ និងការគាំទ្រដល់កម្មវិធីយុត្តិធម៌អនីតិជន។[24] បទប្បញ្ញត្តិផ្សេងទៀតដូចជា ការត្រួតពិនិត្យតាមផ្លូវតុលាការ និងសេវាសហគមន៍ជាដើមទាមទារឱ្យមានធនធាន និងនីតិវិធីគ្រប់គ្រាន់។ ការទាមទារវិធីសាស្ត្របែបសហប្រតិបត្តិការនេះ រដ្ឋាភិបាលបាននឹងកំពុងធ្វើការងារក្នុងភាពជាដៃគូរជាមួយម្ចាស់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងអង្គការឯកជននានាដើម្បីធានាដល់ការវិវឌ្ឍន៍នៃដំណើរការយុត្តិធម៌អនីតិជនប្រកបដោយប្រសិទ្ធភាព ដែលធានាឱ្យបានថា កុមារដែលរំលោភច្បាប់ទទួលបានការឧបត្ថម្ភគ្រប់គ្រាន់ដើម្បីក្លាយទៅជាសមាជិកស្ថាបនារបស់សង្គម។

## បញ្ហាទូទៅជុំវិញប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ

បញ្ហារាលដាលតាមរយៈប្រព័ន្ធតុលាការកម្ពុជា នោះគឺកង្វះការទទួលបានសិទ្ធិជំនុំជម្រះដោយយុត្តិធម៌ និងការជ្រៀតជ្រែកដ៏ត្រាំត្រែងផ្នែកនយោបាយ។ ការធ្វើទុក្ខបុកម្នេញរបស់នគរបាលទៅលើជនជាប់ចោទដែលត្រូវបានចាប់ខ្លួនទាំងនោះក៏ជាការព្រួយបារម្ភមួយផងដែរ។ ការបរិយាយលម្អិតជុំវិញភាពមិនប្រក្រតីនៃប្រព័ន្ធយុត្តិធម៌គឺហួសពីព្រំដែននៃកំណត់ត្រាសង្ខេបនេះ។

ករណីសិក្សាទី៣

ក្នុងខែមករា ឆ្នាំ២០១៤ មានការតវ៉ានានាបានកើតឡើងក្នុងរាជធានីភ្នំពេញពាក់ព័ន្ធទៅនឹងការទាមទារប្រាក់ឈ្នួលរបស់កម្មកររោងចក្រកាត់ដេរ។ មានការបង្ក្រាបរបស់នគរបាលជាបន្តបន្ទាប់ ដែលបាននាំឱ្យមានការចាប់ខ្លួនអ្នកតវ៉ាជាច្រើននាក់ ឬអ្នកដែលបង្ហាញខ្លួនដែលត្រូវនគរបាលឃើញនៅជិតកន្លែងតវ៉ានោះ។ មនុស្ស២៦នាក់ត្រូវបានតុលាការចោទប្រកាន់ និងកាត់ទោសពីបទ "*ហិង្សាដោយមានស្ថានទម្ងន់ទោស*" និងពីបទ "*ធ្វើឱ្យខូចខាតដោយចេតនាមានស្ថានទម្ងន់ទោស*"។ ជនជាប់ចោទមួយរូបក្នុងចំណោមជនជាប់ចោទទាំងនោះគឺជាអនីតិជនមានអាយុ១៧ឆ្នាំ។

ការកាត់ទោស និងការជំនុំជម្រះទៅលើជនជាប់ចោទទាំងនោះ ត្រូវបានគេមើលឃើញជាទូទៅថាមានហេតុផលនយោបាយ និងទទួលការរិះគន់ជាខ្លាំងពីសហគមន៍អន្តរជាតិ។ ក្តីបារម្ភលើសពីនេះទៀតនោះគឺការប្រព្រឹត្តមិនសមរម្យទៅលើអនីតិជនអាយុ១៧ឆ្នាំ នៅពេលចាប់ខ្លួន និងពេលស្ថិតនៅក្នុងមន្ទីរឃុំឃាំងនគរបាល។ អនីតិជនរូបនោះបានថ្លែងនៅពេលសវនាការថា ខ្លួនត្រូវបាននគរបាលវាយបាក់ដៃ ខ្លួនជឿថារបួសនោះធ្វើឲ្យគាត់មិនអាចត្រឡប់ទៅធ្វើការងារនៅរោងចក្របានវិញនោះទេ។ អនីតិជននោះត្រូវបានតុលាការកាត់ទោសជាមួយមនុស្សពេញវ័យ ដោយគ្មានការពិចារណាច្បាស់លាស់ដល់អាយុរបស់គាត់។

[23] កិច្ចសន្ទនារបស់ ម.ស.ម.ក ជាមួយចៅក្រមពីររូប គឺចៅ អ៊ឹម វណ្ណៈ និងចៅក្រម ជាម ច័ន្ទពិសិដ្ឋ ថ្ងៃទី ២៩ ខែសីហា ឆ្នាំ២០១៣។

[24] គម្រោងជំនួយផ្នែកយុត្តិធម៌ព្រហ្មទណ្ឌកម្ពុជា ដំណាក់កាលទី ៣ យុត្តិសាស្ត្រយុត្តិធម៌អនីតិជន ដំណោះស្រាយយុត្តិធម៌សកល (អាស៊ី) ខែមិនា ឆ្នាំ២០០៩ (របាយការណ៍) អាចរកបានតាមរយៈ ៖ http://bit.ly/1sTEOti។

អនីតិជននោះ ជាមួយនឹងជនជាប់ចោទដទៃទៀត ត្រូវបានតុលាការរកឃើញពិរុទ្ធភាព និងព្យួរទោសជាប់ពន្ធនាគារ បើទោះជាកង្វះភស្តុតាងភ្ជាប់រូបគាត់ទៅនឹងបទល្មើសក៏ដោយ។

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

កម្ពុជាពិតជាមានក្របខ័ណ្ឌច្បាប់ចែងពីអនីតិជនក្នុងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ដែលអនុលោមតាមវិសាលភាពច្បាស់លាស់នឹងបទដ្ឋានអន្តរជាតិ។ ប៉ុន្តែ ក្តីព្រួយបារម្ភចម្បងជុំវិញច្បាប់នេះ និងនីតិវិធីសម្រាប់អនុវត្តទៅលើអនីតិជន។ ក្តីបារម្ភទាំងនេះ ស្ថិតក្នុងលក្ខណៈវិនិច្ឆ័យធំៗចំនួនពីរ។ ទីមួយ ដូចបានជ្រាបខាងលើហើយ ច្បាប់ដែលកំពុងតែជរមានពុំទាន់មានលក្ខណៈគ្រប់គ្រាន់ មានគំលាតគ្នាក្នុងច្បាប់នោះដែលធ្វើឱ្យពុំមានប្រសិទ្ធភាព។ ទីពីរ កិច្ចការពារតាមច្បាប់ និងនីតិវិធីមិនត្រូវបានប្រកាន់ខ្ជាប់ខ្ជួនតាមការអនុវត្តន៍ជាក់ស្តែង។

កង្វះការកំណត់ផ្នែកវិធាននីតិវិធីដែលចែងច្បាស់លាស់អំពីអនីតិជនគឺជាកត្តារួមចំណែកសំខាន់មួយ។ ក្នុងចំណោមបទប្បញ្ញត្តិក្នុងក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌបានចែងសំដៅទៅលើអនីតិជន ដែលភាគច្រើននៃបទប្បញ្ញត្តិទាំងនេះអោយនិយមន័យសង្ខេប និងទន់ខ្សោយណាស់ចំពោះទង្វើដែលជាការណែនាំពិតប្រាកដដល់ការរៀបចំយុត្តិធម៌អនីតិជន។

ព្រោះដូច្នោះ ម.ស.ម.ក ផ្តល់អនុសាសន៍ដូចខាងក្រោម ៖

- រដ្ឋាភិបាលត្រូវធានាថា ពង្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវបានអនុម័តជារឿងអាទិភាព។ ច្បាប់ត្រូវតែដាក់បញ្ចូលការណែនាំអោយបានត្រឹមត្រូវពីរបៀបផ្តល់ការពិនិត្យនានាទៅលើអនីតិជន ឧទាហរណ៍ លើភាពឯកជន ការអនុវត្តន៍ការឃុំខ្លួនបណ្តោះអាសន្ន។ នេះគួរតែមានការតស៊ូមតិដើម្បីឱ្យមានការអនុវត្តន៍ជម្រើសផ្សេងចំពោះទោសជាប់ឃុំ ផ្តោតសំខាន់លើការអប់រំ សមាហរណ៍កម្ម និងនីតិសម្បទា ហើយត្រូវបង្កើតឱ្យមានកិច្ចពិគ្រោះយោបល់ជាមួយអ្នកអនុវត្តច្បាប់ និងសង្គមស៊ីវិល។
- ចៅក្រមស៊ើបសួរ គួរតែធានាថា បទប្បញ្ញត្តិនានានៃច្បាប់ជាតិ និងច្បាប់អន្តរជាតិ ដែលបង្កើតសច្ចធារណ៍រឹងមាំប្រឆាំងទៅនឹងការឃុំខ្លួនបណ្តោះអាសន្នទៅលើអនីតិជន ត្រូវបានប្រកាន់ខ្ជាប់ខ្ជួន។ ការឃុំខ្លួនបណ្តោះអាសន្នអាចធ្វើឡើងតែក្នុងកាលៈទេសៈពិសេសតែប៉ុណ្ណោះ ជាវិធានការចុងក្រោយបង្អស់ និងក្នុងរយៈពេលសមរម្យខ្លីបំផុត។
- នៅមុនពេលកាន់សំណុំរឿង ឬលើកករណីពាក់ព័ន្ធជាមួយអនីតិជនមកកាត់ទោស ចៅក្រម និងព្រះរាជអាជ្ញាគួរតែទទួលបានការបណ្តុះបណ្តាលច្បាស់លាស់អំពីបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌អនីតិជន ការបណ្តុះបណ្តាលនេះគួរតែត្រូវអនុវត្តរួមគ្នាដោយក្រសួងយុត្តិធម៌ និងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ("គ.ម.ក")។

- ប្រសិនជាអាច នៅក្នុងតុលាការដែលមានបន្ទប់សវនាការច្រើន ពេលជំនុំជម្រះក្តីម្តងៗ គួរតែមានការរៀបចំបន្ទប់ដាច់ដោយឡែកដើម្បីធ្វើឱ្យដាច់ស្រឡះជាមួយករណីពាក់ព័ន្ធនឹងអនីតិជន។ ហាមការចូលរួមជាសាធារណៈ (ឪពុកម្តាយ/អាណាព្យាបាលរបស់ជនជាប់ចោទជាអនីតិជន) គួរត្រូវបានអនុញ្ញាត និងត្រូវធ្វើការរឹតត្បិតការធ្វើរបាយការណ៍នានា។ ក្នុងករណីមិនអាចរៀបចំបន្ទប់សវនាការដាច់ដោយឡែកបានទេនោះ សាធារណៈជនមិនត្រូវបានគួរអនុញ្ញាតអោយចូលរួមសវនាការនោះទេ ហើយឈ្មោះរបស់កុមារ ឬព័ត៌មានលម្អិតពីអត្តសញ្ញាណដទៃៗទៀត នឹងមិនត្រូវបានគេដាក់បង្ហាញនៅលើបញ្ជរផ្តល់ព័ត៌មាននោះឡើយ។
- អនីតិជនគ្រប់រូបមានសិទ្ធិមានមនុស្សពេញវ័យជាតំណាង (ឪពុកម្តាយ/អាណាព្យាបាល ឬបុគ្គលមាននីតិសម្បទាមានអាយុលើសពី១៨ឆ្នាំ) ក្នុងអំឡុងពេលសាកសួររបស់នគរបាល និងនៅគ្រប់សវនាការតុលាការ។
- ការកាត់ទោសទៅលើអនីតិជនត្រូវតែមានជម្រើសច្រើនយ៉ាង។ ក្រសួងយុត្តិធម៌ គាំទ្រដោយក្រសួងសង្គមកិច្ច គួរតែអនុវត្តនូវសំណុំនៃគោលការណែណែនាំស្តីពីការកាត់ទោសពាក់ព័ន្ធនឹងអនីតិជន តាមរយៈការផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្លាំងទៅលើនីតិសម្បទា ជាជាងការផ្តន្ទាទោសតែម្យ៉ាង។ ការដាក់ពន្ធនាគារកុមាការត្រូវតែបញ្ចៀសនៅគ្រប់កាលៈទេសៈទាំងអស់ ហើយគួរត្រូវបានអនុវត្តតែក្នុងករណីធ្ងន់ធ្ងរបំផុតតែប៉ុណ្ណោះ ក្នុងករណីទម្រង់នៃការកាត់ទោសដទៃៗទៀតត្រូវបានប្រើប្រាស់អស់លទ្ធភាពហើយ ឬក្នុងករណីដាក់ពន្ធនាគារជាហេតុផលតម្រូវដើម្បីការការពារសាធារណៈជន ហើយ,
- ក្រសួងយុត្តិធម៌ និងក្រសួងសង្គមកិច្ច គួរតែអនុវត្តគម្រោងផ្សេងទៀត ដែលជនល្មើសជាអនីតិជនត្រូវទទួលបានការឧបត្ថម្ភ និងផ្តល់នីតិសម្បទានៅក្នុងសហគមន៍ដែលជាជម្រើសផ្សេងក្រៅពីការកាត់ទោសផ្លូវការ។ គម្រោងការនេះត្រូវតែធ្វើឡើងនៅមុនដំបូងសម្រាប់អ្នកប្រព្រឹត្តល្មើសគ្រប់រូបលើកលែងតែបទល្មើសឧក្រិដ្ឋធ្ងន់ធ្ងរបំផុត។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន ប៊ុនធឿន អ្នកសម្របសម្រួលគម្រោងសង្កេតការណ៍សវនាការ នៃ ម.ស.ម.ក តាមរយៈទូរសព្ទ ៖ ៨៥៥ (0) ១២ ៤៨ ៣៥ ៤៦ ឬតាមរយៈអ៊ីម៉ែល៖** bunthoeun@cchrcambodia.org។

CC BY NC SA